វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

រាជរដ្ឋាភិបាលកម្ពុជា

អនុក្រឹត្យ/១១៦ អនក្រ.បក/១៧ ធ្នូ ១៩៩៩

## អនុក្រឹត្យស្តីពីការគ្រប់គ្រង ការផលិត និង ការធ្វើអាជីវកម្មផែនទីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ ១៩៩៧

### សំរេច

មាត្រា ១

អនុក្រឹត្យនេះមានគោលដៅទប់ស្កាត់ការផ្សព្វផ្សាយ ការប្រើប្រាស់ជាសាធារណៈនូវផែនទី ដែលមិនឆ្លើយតបទៅនឹងលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយតំរូវអោយមានការគ្រប់គ្រងលើការផលិត និងការធ្វើអាជីវកម្មលើផែនទីគ្រប់ប្រភេទនៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា ២

អគ្គនាយកដ្ឋានសុរិយោដី និង ភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ជាស្ថាប័នតែមួយគត់ ដែលមានភារៈកិច្ចកសាងផែនទីភូមិសាស្ត្រគោល ឬ ផែនទីថានលេខានៃព្រះរាជាណាចក្រកម្ពុជា និង គ្រប់គ្រងត្រួតពិនិត្យរាល់ការបោះពុម្ពផ្សាយផែនទីគ្រប់ប្រភេទរបស់ព្រះរាជាណាចក្រកម្ពុជា សំដៅអោយឯកភាពទូទាំងប្រទេស ។

មាត្រា ៣

រាល់ការកសាងផែនទីជំនាញគ្រប់ប្រភេទតាមជំនាញរបស់អង្គភាពនីមួយ ៗ ត្រូវសហការ និង ប្រើប្រាស់ទិន្នន័យផែនទីគោលរបស់នាយដ្ឋានភូមិសាស្ត្រ នៃអគ្គនាយកដ្ឋានសុរិយោដី និង ភូមិសាស្ត្រ ហើយត្រូវផ្តល់ជូនមកអគ្គនាយកដ្ឋានសុរិយោដី និង ភូមិសាស្ត្រ នូវផែនទីដែលបានកសាងហើយចំនួន ពីរ ច្បាប់ ដើម្បីតំកល់ទុកជាឯកសារ ។

រាល់ការបោះពុម្ពផ្សាយផែនទីកម្ពុជាគ្រប់ប្រភេទ ទំាងនៅក្នុងប្រទេស ឬ ក្រៅប្រទេស សំរាប់ធ្វើអាជីវកម្ម ត្រូវមានការអនុញ្ញាតិ និងចុះទិដ្ឋាការពី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ជាមុន ។

ការនាំចូល ការប្រើប្រាស់ជាសាធារណៈ អាចធ្វើបានចំពោះតែផែនទីដែលមានទិដ្ឋាការពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

មាត្រា ៤:

ជនណាដែលបានធ្វើការចម្លង ឬ ថតចម្លង ឬ កែឆ្នៃខុសពីច្បាប់ដើមនូវរាល់ទិន្នន័យផែនទីគោល ធ្វើការបោះពុម្ពផ្សាយផែនទី ដោយមិនស្របតាមមាត្រា ៣ នៃអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

មាត្រា ៥:

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦:

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ក្រសួង និង ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង ៗ ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។